# មេរៀនទី ៥0: ជនជាតិអ៊ីស្រាអែលរងទុក្ខជាទាសករ

## និក្ខមនំ ៥:១- ៦:១

**គោលបំណង៖** ព្រះគឺជាសេចក្ដីសង្ឃឹមរបស់យើង។

**ខគម្ពីរចងចាំ៖ យេរេមា ២៩:១១** *"ដ្បិតព្រះយេហូវ៉ាមានព្រះបន្ទូលថា អញស្គាល់សេចក្ដីដែលអញគិតពីដំណើរឯងរាល់គ្នា មិនមែនគិតធ្វើសេចក្ដីអាក្រក់ទេ គឺគិតឲ្យបានសេចក្ដីសុខវិញ ដើម្បីដល់ចុងបំផុតឲ្យឯងរាល់គ្នាបាន សេចក្ដីសង្ឃឹម"*

**ការថ្វាយបង្គំសំរាប់គ្រូ៖ (សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្ដើមបង្រៀន)**

ព្រះមិនសន្យាជាមួយអ្នកដែលដើរតាមទ្រង់ថាជីវិតគេងាយស្រួលរហូតនោះទេ ប៉ុន្ដែក្នុងនាមជាអ្នកដើរតាមព្រះយេស៊ូវយើងតែងតែមានសង្ឃឹមទោះបីស្ថិតក្នុងស្ថានភាពលំបាកក៏ដោយ។ ជនជាតិហេព្រើបាត់បង់ក្ដីសង្ឃឹម ហើយយើងពិតជាអាចយល់បានថាមកពីហេតុអ្វី! ប៉ុន្ដែព្រះមិនដែលបោះបង់ផែនការសម្រាប់អនាគតរបស់ពួកគេឡើយ។ នៅថ្ងៃនេះតើអ្វីជាក្ដីសង្ឃឹមរបស់អ្នក? សូមចងចាំថាព្រះកំពុងធ្វើការសំរាប់អនាគតរបស់អ្នក បើទោះបីជាវាមើលទៅហាក់ដូចជាមិនអាចទៅរួចក៏ដោយ។ សូមអរគុណព្រះយេស៊ូវចំពោះវត្តមានរបស់ទ្រង់នៅក្នុងជីវិត រស់នៅរបស់អ្នក។

**ចំរៀង៖** ១. ព្រះយេស៊ូវគ្រីស្ទជាព្រះអម្ចាស់ ២.ខ្ញុំចូលតាមទ្វារព្រះអង្គ ៣. ខ្ញុំនឹងទុកចិត្តទ្រង់

**១. អធិស្ឋាន** *(សូមនាំកុមារអធិស្ឋានបើក)*

**២. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

### ៣. ល្បែងកំសាន្ដ




**សម្ភារៈដែលត្រូវការ៖** ពែង២, ទឹក, ស្ករស និង អំបិល

ថ្ងៃនេះប្រធានបទនៃមេរៀននិយាយពីសេចក្ដីសង្ឃឹម។

១. យកស្ករសលាយក្នុងទឹកមួយពែង និង មួយពែងទៀតសូមលាយជាមួយអំបិល (កុំឱ្យសិស្សឃើញពេលកំពុងលាយ)។

២. នៅពេលលាយរួចសូមលើកបង្ហាញសិស្សដោយកុំប្រាប់ពួកគេថាតើមួយណាជាទឹកអំបិល និងមួយណាជាទឹកស្ករ។

៣. ជ្រើសរើសសិស្ស ២ នាក់ឡើងមកមុខ ក្នុងចំណោមពួកគេទាំងពីរឲ្យ សិស្សម្នាក់ជាអ្នកជ្រើសរើសកែវទឹកឲ្យសិស្សម្នាក់ទៀតជាអ្នកញ៉ាំ។

៤. សូមសួរទៅកាន់សិស្សទាំងពីរ តើពួកគេរំពឹងថាទឹកដែលនៅក្នុងពែងនោះជាទឹកអ្វី។

៥. បន្ទាប់មកឱ្យកុមារផឹកទឹកនោះ តើវាជាទឹកស្ករ? ឬជាទឹកអំបិល?

៦.បើសិនជាទឹកស្ករ សូមសួរគាត់ថាតើកូនមានអារម្មណ៍យ៉ាងណាដែរនៅពេលដែលកូនទទួលបាននូវអ្វីដែលកូនរំពឹងចង់បាន? ព្រះពិតជាមានអំណាចអស្ចារ្យ ព្រោះទ្រង់អាចប្រទាននូវអ្វីដែលយើងសង្ឃឹមចង់បាន!

៧.បើកុមារផឹកចំទឹកអំបិល សូមសួរគាត់ថាតើកូនមានអារម្មណ៍បែបណានៅពេលដែលមិនទទួលបានអ្វីដែលកូនរំពឹងចង់បាន?

៨.មនុស្សមួយចំនួនអាចគិតថាយើងកំពុងជួបការខកចិត្តព្រោះយើងមិនបានទទួលនូវអ្វីដែលយើងរំពឹងចង់បាន ពេលខ្លះជីវិតគឺបែបនេះហើយ យើងអាចនឹងជួបការខកចិត្ត តែព្រះនឹងមិនដែលធ្វើឱ្យយើងខកចិត្តទេ ដូច្នេះហើយបានជាព្រះគម្ពីរប្រាប់យើងឱ្យដាក់ក្តីសង្ឃឹមនៅលើព្រះមិនមែនលើមនុស្សទេ ព្រះគឺជាសេចក្តីសង្ឃឹមតែ១គត់ដែលនឹងមិនធ្វើឱ្យយើងខកចិត្តឡើយ។

## ៤. ការណែនាំមេរៀន

ការដែលមានក្តីសង្ឃឹមមានន័យថាអ្វីដែលយើងចង់បាននឹងកើតឡើង។ ព្រះតែងតែស្រឡាញ់ ហើយចង់ឱ្យយើងសង្ឃឹមលើអ្វីដែលល្អ ពេលខ្លះព្រះប្រទានពរឱ្យយើងភ្លាមៗនូវអ្វីដែលយើងរំពឹងចង់បាន។ ប៉ុន្តែពេលខ្លះព្រះមានបន្ទូលថា ទេ ពីព្រោះទ្រង់ដឹងថាអ្វីៗទាំងនោះមិនល្អ សម្រាប់យើងទេ ឬដោយសារតែនៅក្នុងព្រះទ័យទ្រង់មានអ្វីដែលល្អប្រសើរជាងនេះសំរាប់យើង។ ហើយពេលខ្លះព្រះមានបន្ទូលថា “ចាំសិន—មិនមែនពេលនេះទេ” ពេលវេលារបស់ទ្រង់គឺល្អឥតខ្ចោះ។ ជនជាតិអ៊ីស្រាអែលដែលជាប់ជាទាសករនៅអេស៊ីព្ទអស់រយៈពេល៤០០ឆ្នាំ! ពួកគេសង្ឃឹមថានឹងមានសេរីភាពឡើងវិញប៉ុន្តែពួកគេត្រូវតែរង់ចាំ។ (គ្រូ៖ សូមនិយាយដោយសង្ខេបពីពេលមួយនៅក្នុងជីវិតរបស់អ្នកនៅពេលដែលអ្នកបានអធិស្ឋានសុំអ្វីមួយដោយសង្ឃឹមចង់បានហើយព្រះបានឆ្លើយតបនូវការអធិស្ឋាននោះ។ សួរសិស្សថាប្រសិនបើពួកគេចង់បានអ្វីមួយ នៅពេលដែលគេអធិស្ឋានសុំហើយព្រះនឹងឆ្លើយតប តើពួកគេនិងសុំអ្វីពីព្រះ។)

## ៥. រឿងនៅក្នុងព្រះគម្ពីរ

ត្រលប់ទៅកាន់សម័យលោកម៉ូសេ ជនជាតិអ៊ីស្រាអែលដែលជារាស្ត្ររបស់ព្រះបានធ្វើជាទាសកររបស់ស្តេចចិត្តអាក្រក់ម្នាក់ឈ្មោះផារ៉ោន។ ផារ៉ោនគឺជាស្តេចនៃប្រទេសអេស៊ីព្ទ គាត់បានធ្វើបាបជនជាតិអ៊ីស្រាអែលជាខ្លាំង។ ជនជាតិអ៊ីស្រាអែលត្រូវធ្វើដុំឥដ្ឋចេញពីភក់ និងចំបើងសំរាប់សាងសង់អាគារឲ្យស្តេចផារ៉ោន។ ផារ៉ោនកាន់តែធ្វើអាក្រក់ដាក់ជនជាតិអ៊ីស្រាអែលពីមួយថ្ងៃទៅមួយថ្ងៃ។ ផារ៉ោនបានឱ្យពួកគេធ្វើការកាន់តែច្រើនឡើងៗ ដោយប្រើសំភារៈជំនួយតិចទៅៗ។ ជនជាតិអ៊ីស្រាអែលខ្លាចផារ៉ោនណាស់។ ព្រះបានលឺសម្រែកទ្រហោយំរបស់រាស្ត្រទ្រង់ ហើយទ្រង់ទតរកមើលនរណាម្នាក់ដែលអាចដឹកនាំជនជាតិអ៊ីស្រាអែលចេញពីភាពជាទាសករនេះបាន។ ព្រះបានជ្រើសរើសម៉ូសេក្នុងចំណោមជនជាតិអ៊ីស្រាអែលទាំងអស់ដើម្បីធ្វើការងារមួយនេះ។ ម៉ូសេមិនមានទំនុកចិត្តទាំងស្រុងថាគាត់អាចដឹកនាំរាស្ត្ររបស់ព្រះបានទេ ប៉ុន្តែគាត់ទុកចិត្តនិងសង្ឃឹមលើព្រះ។ ម៉ូសេនិងជនជាតិអ៊ីស្រាអែលបានរង់ចាំព្រះដើម្បីបង្ហាញផ្លូវពួកគេចេញពីអេស៊ីព្ទ ។ ជនជាតិអ៊ីស្រាអែលបានរង់ចាំហើយចាំទៀត ចាំរហូតដល់ទ្រង់យាងមក! ព្រះបានជួយពួកគេឱ្យរួចផុតពីភាពជាទាសកររបស់ផារ៉ោន។ នោះហើយគឺជាព្រះទ្រង់ធ្វើអ្វីដែលទ្រង់និយាយថាទ្រង់នឹងធ្វើ!

មនុស្សគ្រប់គ្នាសុទ្ធតែជួយបញ្ហា ពេលខ្លះយើងមានអារម្មណ៍ថាយើងនៅឯកា ធុញទ្រាន់ និងក្រៀមក្រំដូចជាជនជាតិអ៊ីស្រាអែលដែរ។ ប៉ុន្តែការចែករំលែកការឈឺចាប់ និង បញ្ហារបស់យើងជាមួយនរណាម្នាក់ធ្វើឱ្យយើងមានអារម្មណ៍ថាមិនឯកាឡើយ វាជួយពង្រឹងនូវសេចក្តីជំនឿរបស់យើង ហើយជួយយើងឱ្យមានក្តីសង្ឃឹមលើព្រះដើម្បី

លើព្រះដើម្បីឱ្យយើងឆ្លងកាត់គ្រាលំបាកនោះ។ ការដែលមានក្តីសង្ឃឹមលើព្រះធ្វើឱ្យយើងរឹងមាំ និងអាចឆ្លងកាត់គ្រាលំបាកទាំងនោះបាន។

**៦. សំនួរពិភាក្សា**

១.តើអ្នកណាបានធ្វើអាក្រក់ដាក់ជនជាតិអ៊ីស្រាអែល? *ផារ៉ោន*

២.តើព្រះបានជ្រើសរើសអ្នកណាដើម្បីសង្គ្រោះជនជាតិអ៊ីស្រាអែល? *ម៉ូសេ*

៣.តើម៉ូសេសង្ឃឹមលើអ្នកណានៅពេលដែលគាត់មិនមានទំនុកចិត្តលើខ្លួនឯង? *ព្រះ*

៤.តើព្រះតែងតែធ្វើអ្វីដែលទ្រង់និយាយថាទ្រង់នឹងធ្វើដែរឬទេ? *បាទ,ចាស់! ព្រះមិនដែលភ្លេចអ្វីដែលទ្រង់សន្យាជាមួយយើងទេ។ ពេលខ្លះយើងត្រូវរង់ចាំ តែព្រះតែងតែធ្វើតាមការសន្យារបស់ទ្រង់*

៥. នៅពេលមានបញ្ហានិងការទុកលំបាក តើប្អូនៗស្វែងរកអ្នកណាឱ្យជួយ? *សូមឱ្យកុមារជាអ្នកឆ្លើយ*

**៧. ល្បែងកំសាន្ត** «ស្វែងរកកំណប់ »

**សម្ភារៈដែលត្រូវការ៖** ក្រដាស១០សន្លឹកដែលមានពាក្យថា “សេចក្តីសង្ឃឹម” សរសេរលើក្រាស់ទាំងនោះ

១.មុនពេលកុមារមកដល់ក្នុងថ្នាក់ គ្រូត្រូវសរសេរពាក្យ “ សេចក្តីសង្ឃឹម” លើក្រដាស ១០សន្លឹកហើយលាក់នៅកន្លែងណាក៏បានក្នុងថ្នាក់រៀន

២. ឱ្យសិស្សដើររកក្រដាសទាំងនោះ ពេលគេមកដល់ថ្នាក់រៀន។

៣. រៀបចំរង្វាន់តូចមួយសម្រាប់អ្នកឈ្នះ (រកក្រដាសឃើញ)។




**៨. ខគម្ពីរចងចាំ** យេរេមា ២៩:១១

**៩. ហាត្ថកម្ម** សូមផាត់ពណ៌រូបភាព **«ជនជាតិអ៊ីស្រាអែលកាលនៅជាទាសករ»**

**១០. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

**១១. អធិស្ឋាន** *(សូមនាំកុមារអធិស្ឋានបិទ)*

សូមសរសេរខគម្ពីរចងចាំ:



សូមសរសេរខគម្ពីរចងចាំ:

